ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ...សហវ...

# ប្រកាស
## ស្តីពី
## ការបង្កើតអង្គភាពភាពជាដៃគូរវាងរដ្ឋនិងឯកជនថ្នាក់កណ្តាល នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ១៥០០ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញសេចក្តីសម្រេចលេខ ០៥០ សហវ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជនរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ត្រូវបានបង្កើតអង្គភាពភាពជាដៃគូរវាងរដ្ឋនិងឯកជនថ្នាក់កណ្ដាល ដែលសរសេរជាអក្សរកាត់ថា “**អ.រ.ឯ.**” និងសរសេរជាភាសាអង់គ្លេសថា “Central Public-Private Partnerships Unit” ស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ជាសេនាធិការ និងជាទាយាទនៃគណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយស្ដីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅ នៃ **អ.រ.ឯ.**។

## ជំពូកទី២

## បេសកកម្មនិងរចនាសម្ព័ន្ធ

**ប្រការ៣.-**

**អ.រ.ឯ.** មានបេសកកម្មជំរុញ សម្របសម្រួល និងគ្រប់គ្រងគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ប្រកបដោយនវានុវត្តភាព និងប្រសិទ្ធភាពខ្ពស់ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ សំដៅរួមចំណែកទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ចរយៈពេលវែង និងបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា។

**ប្រការ៤.-**

**អ.រ.ឯ.** បំពេញតួនាទីនិងភារកិច្ច ដូចខាងក្រោម÷

-ជាសេនាធិការ នៃគណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយស្ដីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

-ផ្ដល់អនុសាសន៍ដល់គណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយស្ដីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន លើការរៀបចំ អនុវត្ត និងធ្វើបច្ចុប្បន្នកម្មគោលនយោបាយស្ដីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

-តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយស្ដីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន និងរាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្តជូនគណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយស្ដីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។ ក្នុងករណីមានវេទយិតភាព ត្រូវស្នើសុំការពិនិត្យ និងសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-ចូលរួមគាំទ្រគណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយស្ដីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ក្នុងការរៀបចំ និងធ្វើបច្ចុប្បន្នកម្មលើក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តនិងគ្រប់គ្រងគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

-សម្របសម្រួលប្រតិបត្តិការគម្រោង ដោយចូលរួមពិនិត្យ និងតាមដានរាល់ការរៀបចំ និងអនុវត្តគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅគ្រប់ដំណាក់កាលទាំងអស់នៃវដ្តគម្រោង និងរាយការណ៍ជូនគណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយស្ដីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។ ក្នុងករណីមានវេទយិតភាព ត្រូវស្នើសុំការពិនិត្យ និងសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-ផ្តល់នូវការគាំទ្រខាងផ្នែកប្រតិបត្តិការដល់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលទទួលបានសិទ្ធិប្រទានក្នុងការចុះកិច្ចសន្យាជាមួយដៃគូឯកជន ដើម្បីកំណត់ វាយតម្លៃ រៀបចំរចនាសម្ព័ន្ធ ធ្វើកិច្ចលទ្ធកម្ម ចុះកិច្ចសន្យា និងគ្រប់គ្រងគម្រោងតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

-គ្រប់គ្រងរាល់មូលនិធិសម្រាប់គាំទ្រដល់ការរៀបចំនិងអភិវឌ្ឍន៍គម្រោង និងមូលនិធិបំពេញផលហិរញ្ញវត្ថុគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដោយផ្អែកតាមលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំជាធរមាន។

-ត្រួតពិនិត្យ និងផ្តល់អនុសាសន៍រួម លើរាល់ការវិភាគលើហានិភ័យពាក់ព័ន្ធ រួមទាំងផលប៉ះពាល់សារពើពន្ធ កាតព្វកិច្ចសារពើពន្ធ និងការលើកទឹកចិត្តផ្នែកសារពើពន្ធ សម្រាប់រៀបចំនិងអភិវឌ្ឍន៍គម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដែលបានពិនិត្យ និងផ្តល់យោបល់ដោយក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យ និងសម្រេច តាមរយៈគណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

-បំពេញភារកិច្ចពាក់ព័ន្ធផ្សេងទៀតតាមការកំណត់របស់ប្រធានគណៈកម្មការអន្តរដឹកនាំការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅក្នុងក្របខ័ណ្ឌ និងបទប្បញ្ញត្តិនៃគណៈកម្មការនេះ។

**ប្រការ៥.-**

**អ.រ.ឯ.** មានរចនាសម្ព័ន្ធ ដូចខាងក្រោម÷

១-ផ្នែកគោលនយោបាយនិងគ្រប់គ្រងចំណេះដឹង

២-ផ្នែកអភិវឌ្ឍន៍គម្រោង

៣-ផ្នែកប្រគល់និងត្រួតពិនិត្យគម្រោង

៤-ផ្នែកកិច្ចការទូទៅ

អង្គការលេខនៃ **អ.រ.ឯ.** ត្រូវបានកំណត់ជាឧបសម្ព័ន្ធ នៃប្រកាសនេះ។

**ប្រការ៦.-**

**អ.រ.ឯ.** ដឹកនាំដោយប្រធានម្នាក់ អមដោយអនុប្រធានមួយចំនួន ជាជំនួយការ។

ប្រធាន **អ.រ.ឯ.** ទទួលបន្ទុកដឹកនាំ និងគ្រប់គ្រងការងារទាំងអស់របស់ **អ.រ.ឯ.**។

អនុប្រធាន **អ.រ.ឯ.** ទទួលបន្ទុកពិនិត្យ និងផ្តល់យោបល់ជូនប្រធាន **អ.រ.ឯ.** លើការងារប្រចាំថ្ងៃរបស់ផ្នែកពាក់ព័ន្ធនៃអង្គភាព។

ផ្នែកនីមួយៗនៃ **អ.រ.ឯ.** ដឹកនាំដោយប្រធានម្នាក់ និងមានសមាជិកមួយចំនួន ជាជំនួយការ។

ប្រធាន និងអនុប្រធាន **អ.រ.ឯ.** ព្រមទាំងប្រធានផ្នែក និងសមាជិកតាមផ្នែកនីមួយៗនៃ **អ.រ.ឯ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់ផ្នែកនៃ អ.រ.ឯ.

**ប្រការ៧.-**

ផ្នែកគោលនយោបាយនិងគ្រប់គ្រងចំណេះដឹង មានតួនាទីនិងភារកិច្ច ដូចតទៅ÷

-គាំទ្រការរៀបចំ និងធ្វើបច្ចុប្បន្នកម្មលើគោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់អនុវត្តនិងគ្រប់គ្រងគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

-តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន និងស្នើវិធានការដោះស្រាយបញ្ហាប្រឈម ព្រមទាំងរាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្តជូនគណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។ ក្នុងករណីមានវេទយិតភាព ត្រូវស្នើសុំការពិនិត្យ និងសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-គ្រប់គ្រងការងារពាក់ព័ន្ធនឹងការរៀបចំ បំពេញបន្ថែម វិភាជន៍ថវិកា និងវាយតម្លៃប្រសិទ្ធភាពនៃការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍គម្រោង (Project Development Facility) ឬមូលនិធិស្រដៀងគ្នានេះ ឬស្នើសុំគោលការណ៍ប្រើប្រាស់កម្រៃជោគជ័យនៃការសម្រេចគម្រោង ដើម្បីផ្តល់ការគាំទ្របច្ចេកទេសដល់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ក្នុងការរៀបចំនិងអភិវឌ្ឍន៍គម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

-ផ្តល់ការគាំទ្រក្នុងការធ្វើអាទិភាពរូបនីយកម្ម និងធ្វើបច្ចុប្បន្នកម្មលើបញ្ជីសំណើគម្រោងបឋម ដើម្បីធ្វើការវិភាជថវិកានៃមូលនិធិអភិវឌ្ឍន៍គម្រោង ឬមូលនិធិស្រដៀងគ្នានេះ សម្រាប់រៀបចំនិងអភិវឌ្ឍន៍គម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ឱ្យទទួលបានប្រសិទ្ធភាពខ្ពស់។

-គ្រប់គ្រងការងារពាក់ព័ន្ធនឹងការរៀបចំ បំពេញបន្ថែម វិភាជន៍ថវិកា និងវាយតម្លៃប្រសិទ្ធភាពនៃការប្រើប្រាស់មូលនិធិបំពេញផលហិរញ្ញវត្ថុគម្រោង (Viability Gap Facility) ឬមូលនិធិស្រដៀងគ្នានេះ ដើម្បីផ្តល់ការគាំទ្រហិរញ្ញវត្ថុ ក្នុងការធ្វើឱ្យគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន មានភាពទាក់ទាញខាងផ្នែកពាណិជ្ជកម្ម និងហិរញ្ញវត្ថុ។

-ផ្សព្វផ្សាយអំពីយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដើម្បីជំរុញការអនុវត្តគម្រោង តាមយន្តការនេះ ដល់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល វិស័យឯកជន និងតួអង្គពាក់ព័ន្ធផ្សេងទៀត។

-ប្រមូល គ្រប់គ្រង និងផ្សព្វផ្សាយព័ត៌មានស្តីពីគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ព្រមទាំងចែករំលែកចំណេះដឹងអំពីយន្តការនេះ តាមរយៈប្រព័ន្ធគ្រប់គ្រងចំណេះដឹង និងការរៀបចំសិក្ខាសាលាបណ្តុះបណ្តាលសម្រាប់អង្គភាព និងបណ្តាក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល វិស័យឯកជន និងតួអង្គពាក់ព័ន្ធផ្សេងទៀត។

-សម្របសម្រួល និងសហការជាមួយដៃគូអភិវឌ្ឍន៍ ឬដៃគូពាក់ព័ន្ធផ្សេងទៀត ដើម្បីស្វែងរកជំនួយបច្ចេកទេស ឬមូលនិធិផ្សេងៗ សម្រាប់អភិវឌ្ឍន៍ជំនាញបច្ចេកទេសក្នុងការអនុវត្តនិងគ្រប់គ្រងគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន និងរៀបចំមូលនិធិផ្សេងៗ ដែលគាំទ្រដល់ការរៀបចំ និងអនុវត្តគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

-គ្រប់គ្រងកិច្ចសន្យា និងទីប្រឹក្សា/ក្រុមហ៊ុនទីប្រឹក្សា ដែលមានតួនាទី និងភារកិច្ចពាក់ព័ន្ធនឹងផ្នែកនេះ។

-បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់ប្រធានអង្គភាព។

**ប្រការ៨._**

ផ្នែកអភិវឌ្ឍន៍គម្រោង មានតួនាទីនិងភារកិច្ច ដូចតទៅ÷

-គាំទ្រផ្នែកប្រតិបត្តិការដល់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលទទួលបានសិទ្ធិប្រទានក្នុងការចុះកិច្ចសន្យាជាមួយដៃគូឯកជន ដើម្បីជ្រើសរើស រៀបចំរចនាសម្ព័ន្ធគម្រោង និងធ្វើកិច្ចលទ្ធកម្ម រហូតដល់ការចុះកិច្ចសន្យាគម្រោងជាស្ថាពរ។

-ធ្វើការវាយតម្លៃលើសំណើគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដោយផ្អែកតាមគោលការណ៍ណែនាំស្តីពីការធ្វើអត្តសញ្ញាណកម្ម និងជ្រើសរើសគម្រោង ឬគោលការណ៍ណែនាំផ្សេងៗទៀត ព្រមទាំងរៀបចំបញ្ជីសំណើគម្រោងបឋម ដែលជាមូលដ្ឋានសម្រាប់ការធ្វើអាទិភាពរូបនីយកម្មបន្ត។

-គ្រប់គ្រងប្រតិបត្តិការប្រចាំថ្ងៃនៃការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍គម្រោង (Project Development Facility) ឬមូលនិធិស្រដៀងគ្នានេះ ឬការប្រើប្រាស់កម្រៃជោគជ័យនៃការសម្រេចគម្រោង ដើម្បីទូទាត់ជូនក្រុមទីប្រឹក្សាប្រតិបត្តិការ (Transaction Advisors) ដែលផ្តល់ការគាំទ្រលើការសិក្សា រៀបចំ និងអភិវឌ្ឍន៍គម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

-ផ្តល់នូវការគាំទ្រចាំបាច់នានាដល់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលទទួលបានសិទ្ធិប្រទាន ក្នុងការចុះកិច្ចសន្យាជាមួយដៃគូឯកជន ដើម្បីពិនិត្យលទ្ធភាពនៃការគាំទ្រហិរញ្ញវត្ថុពីប្រភពថវិកាជាតិ ឬប្រភពថវិកាផ្សេងៗ សម្រាប់សំណើគម្រោងតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដែលអនុលោមតាមគោលការណ៍តម្លៃនៃលុយ (Value for Money)។

-ត្រួតពិនិត្យ និងផ្តល់អនុសាសន៍រួម លើរាល់ការវិភាគលើហានិភ័យពាក់ព័ន្ធ រួមទាំងផលប៉ះពាល់ កាតព្វកិច្ច និងការលើកទឹកចិត្តផ្នែកសារពើពន្ធ សម្រាប់រៀបចំនិងអភិវឌ្ឍន៍គម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដែលបានពិនិត្យ និងផ្តល់យោបល់ដោយក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិនិត្យ និងសម្រេច តាមរយៈគណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

-សម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ក្នុងការពិនិត្យ និងវាយតម្លៃរាល់ទិដ្ឋភាពបច្ចេកទេស ទិដ្ឋភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទិដ្ឋភាពច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងទិដ្ឋភាពសង្គម និងបរិស្ថាន ពាក់ព័ន្ធនឹងសំណើគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

-ផ្តល់ការគាំទ្រក្នុងការពិនិត្យ និងអនុម័តសំណើគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដោយគណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

-បុរេជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា ដែលមានលក្ខណៈសម្បត្តិ និងគុណវុឌ្ឍិគ្រប់គ្រាន់ ក្រោមកិច្ចសន្យាផ្តល់សេវាកម្មគ្មានកាលកំណត់ (Indefinite Delivery Contract) និងផ្តល់ការគាំទ្រដល់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ក្នុងការជ្រើសរើសក្រុមទីប្រឹក្សាប្រតិបត្តិការ ពីចំណោមក្រុមហ៊ុនទីប្រឹក្សាដែលបានបុរេជ្រើសរើស។

-ផ្តល់ការគាំទ្រដល់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលទទួលបានសិទ្ធិប្រទាន ក្នុងការចុះកិច្ចសន្យាជាមួយដៃគូឯកជន ដើម្បីបោះផ្សាយសេចក្តីជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យា (Notice of Award) សម្រាប់ការអនុវត្តគម្រោង។

-អភិវឌ្ឍន៍គម្រោងសាកល្បង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដើម្បីដកស្រង់បទពិសោធន៍ពាក់ព័ន្ធនានានឹងការអនុវត្តប្រភេទកិច្ចសន្យាតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ព្រមទាំងកសាងសមត្ថភាពស្ថាប័នតាមរយៈការអនុវត្តអភិក្រម "រៀនផង-ធ្វើផង"។

-គ្រប់គ្រងកិច្ចសន្យា និងទីប្រឹក្សា/ក្រុមហ៊ុនទីប្រឹក្សា ដែលមានតួនាទីនិងភារកិច្ចពាក់ព័ន្ធនឹងផ្នែកនេះ។

-បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់ប្រធានអង្គភាព។

**ប្រការ៩.-**

ផ្នែកប្រគល់និងត្រួតពិនិត្យគម្រោង មានតួនាទីនិងភារកិច្ច ដូចតទៅ៖

-តាមដានវឌ្ឍនភាពនៃការអនុវត្តគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន និងផ្តល់ការគាំទ្រប្រតិបត្តិការ និងគាំទ្រចាំបាច់ផ្សេងៗទៀត ដល់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលទទួលបានសិទ្ធិប្រទានក្នុងការចុះកិច្ចសន្យាជាមួយដៃគូឯកជន នៅក្នុងដំណាក់កាលសាងសង់ ធ្វើប្រតិបត្តិការ និងថែទាំ រហូតដល់ទ្រព្យសម្បត្តិរបស់គម្រោង និងសេវាកម្មពាក់ព័ន្ធ ត្រូវបានប្រគល់ជូនរាជរដ្ឋាភិបាល។

-គ្រប់គ្រងប្រតិបត្តិការប្រចាំថ្ងៃនៃការប្រើប្រាស់មូលនិធិបំពេញផលហិរញ្ញវត្ថុគម្រោង (Viability Gap Facility) ឬមូលនិធិស្រដៀងគ្នានេះ ដើម្បីផ្តល់ការគាំទ្រហិរញ្ញវត្ថុដល់គម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដែលបានឯកភាពជាគោលការណ៍ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-គាំទ្រក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលទទួលបានសិទ្ធិប្រទានក្នុងការចុះកិច្ចសន្យាជាមួយដៃគូឯកជន ក្នុងការស្នើសុំធ្វើវិសោធនកម្មកិច្ចសន្យា ស្នើសុំរំលត់កិច្ចសន្យាជាមួយដៃគូឯកជន ឬទិញយកគម្រោងពីដៃគូឯកជន។

-ចូលរួមតាមដាន និងវាយតម្លៃអំពីផលប៉ះពាល់សារពើពន្ធ កាតព្វកិច្ចសារពើពន្ធ និងការលើកទឹកចិត្តផ្នែកសារពើពន្ធ ដែលកើតចេញពីការអនុវត្តគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

-ត្រួតពិនិត្យ និងវាយតម្លៃគម្រោងពេលកំពុងប្រតិបត្តិការ និងនៅពេលបញ្ចប់កិច្ចប្រតិបត្តិការ ដើម្បីវាយតម្លៃអំពីចំណាយ និងផលប្រយោជន៍ ដែលទទួលបានពីគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន និងដកស្រង់បទពិសោធន៍នានាពីគម្រោងទាំងនោះ ក្នុងគោលបំណងពង្រឹងចំណេះដឹង និងអភិវឌ្ឍន៍សំណើគម្រោងថ្មីឱ្យបានកាន់តែល្អប្រសើរឡើង។

-ពិនិត្យលើរបាយការណ៍វឌ្ឍនភាពនានា រួមទាំងរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគម្រោង ដើម្បីធានាថាដៃគូឯកជនបានបំពេញកាតព្វកិច្ចហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ស្របតាមលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យា។

-ចូលរួមជាមួយក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលទទួលបានសិទ្ធិប្រទានក្នុងការចុះកិច្ចសន្យា ជាមួយដៃគូឯកជន អនុវត្តការដាក់វិធានការចំពោះដៃគូឯកជន ដូចជាការពិន័យ ឬការកាត់បន្ថយការទូទាត់ជូនដៃគូឯកជន។

-គ្រប់គ្រងកិច្ចសន្យា និងទីប្រឹក្សា/ក្រុមហ៊ុនទីប្រឹក្សា ដែលមានតួនាទី និងភារកិច្ចពាក់ព័ន្ធនឹងផ្នែកនេះ។

-បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់ប្រធានអង្គភាព។

**ប្រការ១០.-**

ផ្នែកកិច្ចការទូទៅ មានតួនាទីនិងភារកិច្ច ដូចតទៅ÷

-ជាលេខាធិការដ្ឋានរបស់ **អ.រ.ឯ.**

-ជាច្រកចេញ-ចូល សម្រាប់ឯកសារពាក់ព័ន្ធនឹងការងាររបស់ **អ.រ.ឯ.**

-ជាកន្លែងតម្កល់ឯកសារនិងលិខិតស្នាមផ្សេងៗរបស់ **អ.រ.ឯ.**

-ទទួលបន្ទុកការងារពិធីការរបស់ **អ.រ.ឯ.**

-សម្របសម្រួលរៀបចំគម្រោងថវិកា និងទទួលបន្ទុកការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យរបស់ **អ.រ.ឯ.**

-គ្រប់គ្រងមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យារបស់ **អ.រ.ឯ.**

-សម្របសម្រួលនិងរៀបចំកិច្ចប្រជុំនានារបស់ **អ.រ.ឯ.**

-គ្រប់គ្រង និងធ្វើសារពើភណ្ឌគ្រឿងបរិក្ខារ និងសម្ភារៈការិយាល័យរបស់ **អ.រ.ឯ.**

-រៀបចំ គ្រប់គ្រង និងថែរក្សាប្រព័ន្ធព័ត៌មានវិទ្យារបស់ **អ.រ.ឯ.**

-រៀបចំ និងគ្រប់គ្រងគេហទំព័ររបស់ **អ.រ.ឯ.**

-បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់ប្រធានអង្គភាព។

## ជំពូកទី៤

## ការគ្រប់គ្រងនិងកិច្ចដំណើរការ

### ផ្នែកទី១: បុគ្គលិករបស់ អ.រ.ឯ.

**ប្រការ១១.-**

បុគ្គលិកអចិន្ត្រៃយ៍របស់ **អ.រ.ឯ.** គឺជាមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ ដែលត្រូវបានតែងតាំងឱ្យបម្រើការងារនៅក្នុង **អ.រ.ឯ.** ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងដែលត្រូវបានផ្ទេរពីការិយាល័យសម្របសម្រួលការអភិវឌ្ឍផ្នែកឯកជននៃនាយកដ្ឋានវិនិយោគនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយរក្សានូវមុខតំណែង ឋានន្តរសក្តិ និងអតីតភាពការងារដដែល។

អ.វ.ជ. ត្រូវបានអនុញ្ញាតឱ្យជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ដើម្បីបំពេញការងារតាមតម្រូវការចាំបាច់របស់ខ្លួន ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ ដែលបំពេញភារកិច្ចនៅ អ.វ.ជ. ទទួលបានការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗពីថវិការដ្ឋ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗក្រៅពីថវិការដ្ឋ ជូនបុគ្គលិកអចិន្ត្រៃយ៍ និងបុគ្គលិកជាប់កិច្ចសន្យា នៃ អ.វ.ជ. ត្រូវសម្រេចជាគោលការណ៍ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អ.វ.ជ. អាចស្នើសុំផ្ទេរបុគ្គលិកដែលមានជំនាញខ្ពស់ ឬទទួលវិក្រឹតការី ឬកម្មសិក្សាការី ពីក្រសួង-ស្ថាប័នផ្សេងៗជាបណ្តោះអាសន្ន (Secondment) ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍ទៅវិញទៅមក ក្នុងគោលបំណងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអនុវត្ត និងគ្រប់គ្រងគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

## ផ្នែកទី២: កិច្ចដំណើរការការងារ

**ប្រការ១២.-**

អ.វ.ជ. អាចស្នើសុំកិច្ចសម្របសម្រួល និងសហប្រតិបត្តិការពីគ្រប់ស្ថាប័ន និងអង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងផ្តល់យោបល់លើការរៀបចំ និងអភិវឌ្ឍន៍គម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

អ.វ.ជ. ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅក្នុងការបំពេញការងារ។

**ប្រការ១៣.-**

អ.វ.ជ. មានរបបប្រជុំប្រចាំខែ ត្រីមាស និងឆ្នាំ ដោយមានការចូលរួមពីគ្រប់សមាសភាពជាអនុប្រធានអង្គភាព ប្រធានផ្នែក និងសមាជិកនៃអង្គភាពភាពជាដៃគូរវាងរដ្ឋនិងឯកជនថ្នាក់កណ្តាល ក្រោមការដឹកនាំរបស់ប្រធាន អ.វ.ជ.។

**ប្រការ១៤.-**

ផ្នែកនីមួយៗនៃ អ.វ.ជ. មានរបបប្រជុំប្រចាំសប្តាហ៍ ដើម្បីពិនិត្យតាមដានវឌ្ឍនភាពការងារ កំណត់ និងដោះស្រាយបញ្ហាប្រឈម ក្នុងការអនុវត្តការងាររបស់ខ្លួន។ អនុប្រធាន អ.វ.ជ. អាចដឹកនាំ និងសម្របសម្រួលកិច្ចប្រជុំប្រចាំសប្តាហ៍ ឬកិច្ចប្រជុំចំពោះកិច្ចនៃផ្នែកពាក់ព័ន្ធ តាមការចាំបាច់។ ក្នុងករណីមានបញ្ហាប្រឈម អនុប្រធាន អ.វ.ជ. ត្រូវរាយការណ៍ជូនប្រធាន អ.វ.ជ. ដើម្បីពិនិត្យ និងសម្រេច តាមការចាំបាច់។

## ផ្នែកទី៣: ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យរបស់ អ.វ.ជ.

**ប្រការ១៥.-**

អ.វ.ជ. ត្រូវមានគណនេយ្យភាពចំពោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការងារគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១៦.-**

ប្រធាន អ.វ.ជ. ជាអាណាប័កផ្ទេរសិទ្ធិនៃថវិការបស់ អ.វ.ជ. ដែលទទួលបានការប្រគល់សិទ្ធិពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាអាណាប័កដើមខ្សែ ដោយមានសិទ្ធិអំណាច ដូចតទៅ÷

-បញ្ញា និងជម្រះចំណូល

-បញ្ញាចំណាយ ជម្រះបញ្ជី និងចេញអាណត្តិបើកប្រាក់។

ក្នុងនាមអាណាប័កផ្ទេរសិទ្ធិ ប្រធាន អ.វ.ជ. អាចផ្ទេរសិទ្ធិនេះបន្តឱ្យអាណាប័កជំនួស ដោយមានការយល់ព្រមពីអាណាប័កដើមខ្សែ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវតែងតាំងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់ អ.វ.ជ. តាមសំណើរបស់ប្រធាន អ.វ.ជ. ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុនៅ អ.វ.ជ.។ មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវមានលក្ខណៈសម្បត្តិ ដូចខាងក្រោម÷

-មានកម្រិតវប្បធម៌មិនតិចជាងបរិញ្ញាប័ត្រផ្នែកសេដ្ឋកិច្ច ឬផ្នែកហិរញ្ញវត្ថុ ឬផ្នែកពាក់ព័ន្ធ

-មានបទពិសោធន៍ការងារផ្នែកសេដ្ឋកិច្ច ឬផ្នែកហិរញ្ញវត្ថុ ឬផ្នែកពាក់ព័ន្ធ យ៉ាងតិច ០៣ ឆ្នាំ

-ធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកហិរញ្ញវត្ថុសាធារណៈ។

ការបង្កើតរជ្ជទេយ្យចំណូល និង/ឬរជ្ជទេយ្យបុរេប្រទាន ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីទទួលបានសំណើពីប្រធាន អ.វ.ជ.។

**ប្រការ១៧.-**

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងការកាន់កាប់បញ្ជីកាគណនេយ្យ ត្រូវអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ។

គណនេយ្យករត្រូវមានគុណវុឌ្ឍិ ព្រមទាំងបទពិសោធន៍វិជ្ជាជីវៈច្បាស់លាស់ និងបំពេញលក្ខខណ្ឌផ្សេងទៀត ដែលស្របតាមបទប្បញ្ញត្តិជាធរមាន។ គណនេយ្យករ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គណនេយ្យករមានភារកិច្ច÷

-គ្រប់គ្រងការប្រមូលចំណូល

-ទូទាត់ចំណាយ

-រក្សាទុក និងគ្រប់គ្រងការប្រើប្រាស់នូវមូលនិធិ និងវត្ថុមានតម្លៃ

-រក្សាទុកនូវលិខិតយុត្តិការ និងកាន់កាប់បញ្ជីកាគណនេយ្យ

-ចូលរួមរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់ អ.វ.ជ.។

គណនេយ្យករអាចមានមន្ត្រីជំនាញមួយចំនួនជាជំនួយការ ក្នុងការបំពេញមុខងាររបស់ខ្លួន។

**ប្រការ១៨.-**

ប្រភពធនធានរបស់ អ.វ.ជ. រួមមាន÷

-ធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-អំណោយ ជំនួយ និងអច្ច័យទានដែល អ.វ.ជ. ទទួលបាន

-មូលនិធិពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការបរទេស

-កម្រៃជោគជ័យនៃការសម្រេចគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ស្របតាមការកំណត់នៃច្បាប់ និងបទប្បញ្ញត្តិជាធរមាន

-ប្រភពផ្សេងទៀត តាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ១៩.-**

ចំណូល ចំណាយចរន្ត និងមូលធនរបស់ អ.វ.ជ. ត្រូវគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់ អ.វ.ជ. និងត្រូវឆ្លុះបញ្ចាំងជាឧបសម្ព័ន្ធនៃថវិកាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ២០.-**

ត្រូវបានទុកជានិរាករណ៍៖

-ចំណុចទី៦ នៃប្រការ៣៥ នៃប្រកាសលេខ ១៥០០ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

-ប្រការ៣ និង៤ នៃសេចក្ដីសម្រេចលេខ ០៥០ សហវ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦ ស្ដីពីការបង្កើតគណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយស្ដីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជនរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ២១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២២.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំ នព្វស័ក ព.ស. ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយស្ដីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន
- ដូចប្រការ២២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃប្រកាសលេខ [illegible]

ចុះថ្ងៃទី ២២ ខែ [illegible] ឆ្នាំ ២០១៧

## <u>អង្គការលេខនៃអង្គភាពភាពជាដៃគូរវាងរដ្ឋនិងឯកជនថ្នាក់កណ្ដាល</u>

